# សង្គ្រាមជាមួយវៀតណាម និងជម្លោះនៅអន្តរជាតិជុំវិញជម្រះទិសាមញ្ញក្នុងតុលាការកម្ពុជា

ដោយ ឡូរ៉ា ម៉ាក់ដូណល់

ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩

*ប្រែសម្រួលដោយ ខែន សុខស្រីនិត*

## ជនស៊ីវិល អ្នកយកការណ៍ និងខ្មាំងសត្រូវជនជាតិវៀតណាមនៅមន្ទីរស-២១

ថ្ងៃនេះ កាំង ហ្គេកអ៊ាវ (ឌុច) បានបញ្ចប់កសិណសាក្សីរបស់ខ្លួនទាក់ទិននឹងជម្លោះប្រដាប់អាវុធរវាងកម្ពុជា និងវៀតណាម ដែលបានកើតមានឡើងក្នុងអំឡុងរបបខ្មែរក្រហមចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

ដោយផ្អែកលើការយល់ដឹងនាពេលថ្មីៗនេះ ឌុច មិនបានបដិសេធចំពោះការអះអាងដែលថា សង្គ្រាមរវាងកម្ពុជា និងវៀតណាមបានចាប់ផ្តើមក្នុងខែមេសា ឆ្នាំ១៩៧៥ ប៉ុន្តែ ឌុច បានបញ្ជាក់ថា ខ្លួនបានដឹងតិចពីជម្លោះនេះដែលបានកើតឡើងក្នុងអំឡុងពេលមុនថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ តិចតួចណាស់ ។ ឌុច បានអះអាងថា សុន សេន ថ្នាក់លើដែល ឌុច តែងតែនិយាយជារៀងរាល់ថ្ងៃនោះ បានចុះធ្វើសមរភូមិដោយសារតែកត្តាចាំបាច់នៃជម្លោះនេះកាលពីឆ្នាំ១៩៧៧ ហើយចំណែកឯ ឌុច វិញមិនបានដឹងពីអ្វីទាំងអស់ដែលបានកើតឡើង ។ ចៅក្រម ស៊ីលយ៉ា ខាត់វ៉ាយថ៍ ព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមបានព្យាយាមប្រានចោលនូវសេចក្តីអះអាងនេះពេញរយៈពេលមួយថ្ងៃ ប៉ុន្តែ ឌុច នៅតែប្រកាន់ជំហរថា ថ្នាក់លើរបស់ ឌុច គ្រាន់តែផ្តល់សេចក្តីបង្គាប់ពីរបៀបគ្រប់គ្រងគុកទួលស្លែង (មន្ទីរស-២១) តែប៉ុណ្ណោះ ហើយថា ថ្នាក់លើរបស់ ឌុច មិនដែលចែករំលែកព័ត៌មានទាក់ទិននឹងព្រឹត្តិការណ៍ថ្មីៗដែលបានកើតឡើងជាមួយនឹង ឌុច ឡើយ ។

ឌុច បានពន្យល់ថា អ្នកទោសជនជាតិវៀតណាមត្រូវបានបែងចែកជាជនស៊ីវិល អ្នកយកការណ៍ ឬសេនាជនដោយថ្នាក់លើរបស់ ឌុច ។ ឌុច ក៏បានទទួលស្គាល់ថា ខ្លួនមិនបានត្រួតពិនិត្យពីភាពត្រឹមត្រូវនៃការបញ្ជាររបស់ថ្នាក់លើទាំងនោះឡើយ ពីព្រោះថា យោងតាមគោលនយោបាយទូទៅរបស់មន្ទីរស-២១ អ្នកទោសទាំងអស់ដែលបញ្ជូនមកមន្ទីរស-២១ត្រូវតែសម្លាប់ចោល ។ ស្របពេលដែល ឌុច ទទួល

ស្គាល់ថា ជនស៊ីវិល និងអ្នកយកការណ៍ជនជាតិវៀតណាមមួយចំនួនបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ មុនឆ្នាំ១៩៧៨ ឌុច ក៏បានពន្យល់ថា ខ្មាំងសង្គ្រាមជនជាតិវៀតណាមបានចាប់ផ្តើមបញ្ជូនមកដល់មន្ទីរស-២១ក្នុងចំនួនដ៏ច្រើនកាលពីខែមករា ឆ្នាំ១៩៧៨។ មុនឆ្នាំ១៩៧៨ ឌុច បាននិយាយថា ខ្លួនត្រូវបានបញ្ជាឲ្យយកចិត្តទុកដាក់លើការទាញយកចម្លើយពីខ្មាំង ប៉ុន្តែនៅពេលដែលខ្មាំងសង្គ្រាមចាប់ផ្តើមមកដល់មន្ទីរស-២១ ឌុច ក៏ត្រូវបានបញ្ជាឲ្យផ្តោតទៅលើការទាញយកចម្លើយសារភាព ដើម្បីផ្សព្វផ្សាយសម្រាប់ការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា។ ឌុច បានសារភាពថា ខ្លួនបានបញ្ជាឲ្យអ្នកសួរចម្លើយប្រើប្រាស់វិធីសាស្ត្រអ្វីក៏បាន ដើម្បីសម្រេចនូវគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការទាញយកនូវចម្លើយសារភាពដែលអាចប្រើប្រាស់បាន។ ឌុច ក៏បាននិយាយផងដែរថាចម្លើយសារភាពជាច្រើនត្រូវបានធ្វើការកែប្រែដោយថ្នាក់លើ ដើម្បីយកមកធ្វើជាការឃោសនាដែលមានប្រសិទ្ធិភាព។ មានពេលខ្លះ ឌុច បានបញ្ជូនបុគ្គលិកមន្ទីរស-២១ទៅកាន់សមរភូមិដើម្បីនាំយកខ្មាំងសង្គ្រាមមកកាន់មន្ទីរស-២១វិញ។

កាលពីម្សិលមិញ ឌុច បានគូសបញ្ជាក់ថា យ៉ាងហោចណាស់ជនជាតិវៀតណាមចំនួន៤០០នាក់ គឺជាជនរងគ្រោះនៅមន្ទីរស-២១។ យ៉ាងណាមិញនៅថ្ងៃនេះ ឌុច បានបញ្ជាក់ថា នៅក្នុងបញ្ជីឈ្មោះអ្នកទោសជនជាតិវៀតណាមត្រឹមតែ៣៨៥នាក់តែប៉ុណ្ណោះ។ បើទោះបីជា ឌុច មិនបានចេញបញ្ជាក៏ដោយ ក៏កម្មាភិបាលនៅមន្ទីរស-២១ ច្បាស់ជាមិនបញ្ចូលឈ្មោះកូនក្មេងជនជាតិវៀតណាមទៅក្នុងបញ្ជីឈ្មោះអ្នកទោស ឬថតរូបក្មេងៗទាំងអស់នោះទេ។ ដូច្នេះ តួរលេខអ្នកទោសជនជាតិវៀតណាម គឺពិតជាមិនត្រឹមត្រូវនោះទេ។ កូនៗរបស់«ខ្មាំង»ត្រូវបានចាត់ទុកថាជាខ្មាំងដែរ ហើយក៏ត្រូវ«កម្ទេច»សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ដូចគ្នាដែរ។

ទាក់ទិនជាមួយនឹងការយល់ដឹងពីច្បាប់អន្តរជាតិស្តីពីខ្មាំងសង្គ្រាម ឌុច បានអះអាងថា គាត់មិនបានដឹងថាសកម្មភាពរបស់គាត់នាពេលនោះប្រឆាំងនឹងច្បាប់អន្តរជាតិទេ រហូតដល់សេចក្តីសន្និដ្ឋានបឋមត្រូវបាន ធ្វើឡើងនាពេលដំណើរការបឋមនៃរឿងក្តីរបស់គាត់។ ឌុច បានទទួលស្គាល់ថា ប្រសិនបើ ឌុច អានច្បាប់អន្តរជាតិនាពេលឥឡូវនេះ វានឹងបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា សកម្មភាពរបស់ ឌុច គឺពិតជា«ខុសទាំងស្រុង»។ ដោយកត់សម្គាល់ឃើញថា ឌុច មិនបានដឹងពីច្បាប់អន្តរជាតិនាពេលនោះ ចៅក្រម ខាតរ៉ាយថ៍ បានជម្រុញសួរ ឌុច ថា «តើ ឌុច មានស្មារតីយល់ពីអារម្មណ៍អ្នកដទៃដែរឬទេ? ជាការឆ្លើយតប ឌុច បានពន្យល់ប្រាប់ថា នាពេលនោះប្រជាជនកម្ពុជានាំគ្នាសម្លាប់ជនជាតិ

វៀតណាម ហើយជនជាតិវៀតណាមក៏បានសម្លាប់ប្រជាជនខ្មែរវិញដែរ ។ ឌុច គ្រាន់តែអនុវត្តបញ្ជាដែលគាត់ទទួលបានតែប៉ុណ្ណោះ ។

ការសួរសំណួរនៅក្នុងថ្ងៃនេះភាគច្រើនក្រៅប្រធានបទ ដោយបែរជាសង្កត់ធ្ងន់ទៅលើដំណើរការប្រតិបត្តិការរបស់មន្ទីរស-២១ទាក់ទិននឹងអ្នកទោសវៀតណាម ជាជាងការយល់ដឹងរបស់ ឌុច ពីជម្លោះប្រដាប់អាវុធអន្តរជាតិទៅវិញ ។ ដោយសារតែមេធាវីការពារក្ដីអន្តរជាតិ ហ្វ្រង់ស៊័រ រូ មិនមានវត្តមានចូលរួម អាស្រ័យថាលោកត្រូវទៅចូលរួមតុលាការព្រហ្មទណ្ឌពិសេសសម្រាប់ប្រទេសឡេបាណន់ក្នុងសប្ដាហ៍នេះ គ្មាននរណាម្នាក់ហ៊ានក្រោកឈរជម្រុញឲ្យមានការយកចិត្តទុកដាក់ពីព្រំដែននៃប្រធានបទពិភាក្សា និងពីភាពជាប់ពាក់ព័ន្ធនោះទេ ។ បន្ទាប់ពីមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីចោទសួរសំណួរមួយមក ឌុច បាននិយាយដោយខ្លួនឯងថា សំណួរនេះខុសប្រធានបទ ហើយបដិសេធមិនឆ្លើយនឹងសំណួរនេះឡើយ ។ គ្មាននរណាម្នាក់បដិសេធនឹងការមិនយល់ព្រមឆ្លើយនឹងសំណួររបស់ ឌុច ឡើយ ។ ឌុច បាននិយាយថា ខ្ញុំជឿជាក់ថា ហ្វ្រង់ស៊័រ រូ ប្រហែលជាជំទាស់នឹងការសួរសំណួរនៅក្នុងថ្ងៃនេះជាច្រើនលើក ហើយវាក៏អាចធ្វើឲ្យដំណើរការនីតិវិធីក្នុងថ្ងៃនេះមានប្រយោជន៍ជាងនេះដែរ ។

## ដំណើរការទៅមុខយ៉ាងប្រញាប់ប្រញាលរបស់អង្គជំនុំជម្រះសេចក្ដីប្រឆាំង ឌុច

ដោយមិនបានរៀបចំឲ្យមានដំណើរការនីតិវិធីដូចធម្មតាសម្រាប់ថ្ងៃស្អែក អង្គជំនុំជម្រះសម្រេចបន្តកិច្ចប្រជុំស្ដីពីដំណើរគ្រប់គ្រងអង្គជំនុំជម្រះដោយសម្ងាត់ជាមួយនឹងភាគីពាក់ព័ន្ធទាំងអស់ រួមទាំងភាគីដែលមិនបានអនុញ្ញាតឲ្យចូលរួមក្នុងកិច្ចប្រជុំនេះកាលពីលើកមុន ។ គោលបំណងទាំងមូលនៃកិច្ចប្រជុំនេះ គឺដើម្បីធានាថា អង្គជំនុំជម្រះអាចដំណើរការទៅមុខឲ្យបានរហ័សតាមតែអាចធ្វើបាន ហើយលោកប្រធាន និល ណុន បានកំណត់របៀបវារៈយ៉ាងជាប់ខាតតែម្ដង ។

ភាគីទាំងអស់នឹងធ្វើការពិភាក្សាពីរយៈពេលសន្មត់មួយ សម្រាប់ដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ដូចជា ចំនួនថ្ងៃដំណើរការអង្គជំនុំជម្រះ រយៈពេលសម្រាករបស់អង្គជំនុំជម្រះ និងពេលវេលាដែលត្រូវផ្ដល់ជូនការធ្វើកសិណសាក្សីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។ ជាមួយគ្នានេះ ភាគីទាំងអស់ក៏ធ្វើការពិភាក្សារាល់បញ្ហាដែលបានកើតមានឡើង ទាក់ទិននឹងចំនួនមេធាវីដែលអាចជួយដល់ដើមបណ្ដឹងរដ្ឋប្បវេណី បញ្ហារដ្ឋបាល និងបុគ្គលិកផងដែរ ។ ជាចុងក្រោយ ដោយធ្វើការលើកឡើងពីប្រធានបទនៃកិច្ច

ប្រជុំស្តីពីការគ្រប់គ្រងអង្គជំនុំជម្រះកាលពីពីរសប្តាហ៍មុននេះ ចៅក្រមទាំងអស់នឹងស្នើសុំឲ្យមានវិសោធនកម្មលើវិធាន៨៧.៣នៃវិធានផ្ទៃក្នុងដែលទាក់ទិននឹងរបៀបដែលភាគីណាមួយ អាចដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះនឹងធ្វើការស្នើសុំដ៏សមហេតុផលមួយដែលថា ក្រៅពីការផ្តល់នូវសេចក្តីសង្ខេបដ៏លម្អិត ឬក៏អាននោះ ឯកសារនេះអាចនឹងត្រូវបាន«កត់សម្គាល់ថា មានលក្ខណៈសមរម្យ»នៅក្នុងអង្គជំនុំជម្រះបានផងដែរ ។ ចៅក្រម ខាតរ៉ាយថ៍ បានលើកឡើងថា អង្គជំនុំជម្រះនឹងស្នើឲ្យមានការបង្កើតវិធានថ្មីមួយ គឺវិធាន៨៧.៦ ដែលនឹងអនុញ្ញាតឲ្យក្រុមចៅក្រមធ្វើការពិចារណាហេតុការណ៍ដែលបានបង្ហាញថាពិតនោះបាន ខណៈពេលដែលទាំងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីមិនជំទាស់នឹងហេតុការណ៍នៃមាននៅក្នុងដីការចោទប្រកាន់ ។

កិច្ចប្រជុំនេះចាប់ផ្តើមធ្វើឡើងបន្ទាប់ពីការធ្វើកសិណសាក្សីរបស់សាក្សីពីររូប ដែលនឹងមកពិភាក្សាពីដំណើរការប្រតិបត្តិរបស់មន្ទីរស-២១ ត្រូវបានពន្យារពេលដោយសារតែដំណើរការនីតិវិធីទាំងនោះបន្តទៅមុខយឺតជាការរំពឹងទុក ។ ជាច្រើនលើកមកហើយនៅក្នុងសប្តាហ៍នេះ ចៅក្រមបានសម្តែងនូវគោលបំណងរបស់ខ្លួនក្នុងការជម្រុញឲ្យមានដំណើរការអង្គជំនុំជម្រះកាន់តែរហ័ស ។ ក្រោយពីអង្គប្រជុំចៅក្រម និងភាគីទាំងអស់បានចាប់ផ្តើមវិលត្រឡប់មកវិញក្រោយពីពេលឈប់សម្រាក ហើយបានចេញរបាយការណ៍សម្រេចមួយថា ការផ្លាស់ប្តូរមួយបានធ្វើឡើងដើម្បីអនុញ្ញាតឲ្យមានការបន្ថែមម៉ោងសម្រាប់ការធ្វើកសិណសាក្សីនីមួយៗជារៀងរាល់ថ្ងៃ ។

## ***សន្និសិទ្ទិកាសែតប្រចាំសប្តាហ៍***
## ***ជនត្រូវចោទជម្រុញឲ្យមានបទដ្ឋានយុត្តិធម៌នៃអង្គជំនុំជម្រះ***

រីចឆាត រ៉ូជី ប្រធានផ្នែកគាំពារការការពារក្តីរបស់ អ.វ.ត.ក គឺជាវាគ្មិននៅក្នុងឱកាសសន្និសិទ្ទិកាសែតសម្រាប់ថ្ងៃនេះ ។ រ៉ូជី បានរៀបរាប់ថា ផ្នែកគាំពារការពារក្តីតម្រូវឲ្យលើកកម្ពស់សិទ្ធិជនត្រូវចោទតាមរយៈការផ្តល់ជាជំនួយដល់មេធាវីការពារក្តី ។ លោកបានរំឭកពីបន្ទប់អ្នកកាសែត ទីនោះ ហើយដែលជំនួយអន្តរជាតិបានធ្វើឡើង ក្នុងគោលបំណងធានាឲ្យមានបទដ្ឋានយុត្តិធម៌នៃអង្គជំនុំជម្រះ ដែលបទដ្ឋានទាំងនេះ គឺជាអ្វីដែលជនត្រូវចោទនិងជនរងគ្រោះចង់បាន ពីព្រោះថា បទដ្ឋានទាំងអស់នេះនឹងធ្វើឲ្យចៅក្រមចេញសេចក្តីសម្រេចដែលត្រឹមត្រូវ ។

រ៉ូជី បានពន្យល់ពីកាតព្វកិច្ចវិជ្ជាជីវៈរបស់មេធាវីការពារក្ដីក្នុងការលើកឡើងពីបញ្ហាការកាត់ទោសប្រកបដោយយុត្តិធម៌ និងបានផ្ដល់ជាឧទាហរណ៍ថ្មីៗមួយចំនួនសម្រាប់សំណុំរឿងលេខ០០២ ដែលរួមមានសំណូមពររបស់មេធាវីការពារក្ដី ស្នើសុំឲ្យមានការផ្ដល់នូវរបាយការណ៍សម្ងាត់មួយពីការិយាល័យត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គការសហប្រជាជាតិ បញ្ហានេះកំពុងតែបង្កឹងខទូរណ៍នៅចំពោះអង្គបុរេជំនុំជម្រះ និងរួមទាំងបញ្ហាសំបុត្ររបស់មេធាវីការពារក្ដីជូនឲ្យសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតទាក់ទិននឹងការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងកិច្ចការរបស់ខ្លួនផងដែរ ។ ដោយធ្វើការបកស្រាយចំពោះ "មតិយល់ច្រឡំ"ទូទៅលើសកម្មភាពរបស់មេធាវីការពារក្ដី រ៉ូជី បានអះអាងថា មេធាវីការពារក្ដីមិនមែនមានគោលបំណងលើកឡើងពីបញ្ហានេះដើម្បីរារាំង ឬពន្យារពេលដំណើរការនីតិវិធី ដោយលោកបានកត់សម្គាល់ថា ក្ដីព្រួយបារម្ភពីការកាត់ទោសប្រកបដោយយុត្តិធម៌មិនមែនជាកត្តារារាំងដល់ដំណើរការរបស់តុលាការឡើយ ហើយដំណើរការស៊ើបអង្កេតក៏នៅតែបន្តធ្វើឡើងដដែល ។ បន្ថែមលើនេះ រ៉ូជី បានអះអាងថា មេធាវីការពារក្ដីមិនមែនកំពុងតែព្យាយាមគេចចេញពីការពិតរបស់រឿងក្ដីនោះទេ ពីព្រោះថា កិច្ចខិតខំឲ្យមានការកាត់ទោសប្រកបដោយយុត្តិធម៌ គឺជួយឃឹតយោងគ្នាទៅវិញទៅមកពីជាជាងយកភស្តុតាងមកជំនួសឲ្យកិច្ចការរបស់មេធាវីការពារក្ដី ។

រ៉ូជី បានពន្យល់បន្ថែមទៀតពីទស្សនៈរបស់មេធាវីការពារក្ដីថា យន្តការរបស់អង្គបុរេជំនុំជម្រះក្នុងការដោះស្រាយការមិនយល់ស្របគ្នារវាងសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា គឺមិនមែនជាដំណោះស្រាយមួយសម្រាប់ការជ្រៀតជ្រែកផ្នែកនយោបាយនោះទេ ។ យោងតាមច្បាប់អន្តរជាតិ សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់ទោសប្រកបដោយភាពយុត្តិធម៌របស់តុលាការអន្តរជាតិបានចែងយ៉ាងច្បាស់លាស់ណាស់ ហើយការខ្វះខាតនូវឯករាជ្យភាពក្នុងការកាត់ទោសមិនអាច ដោះស្រាយបានដោយងាយនោះទេ ពីព្រោះថា ជម្លោះនេះនឹងត្រូវបញ្ជូនទៅអង្គបុរេជំនុំជម្រះ ។

ដោយធ្វើការលើកឡើងពីការព្រួយបារម្ភផ្សេងៗទៀត រ៉ូជី បានរៀបរាប់ពីការខ្វះខាតនូវព័ត៌មានផ្នែកថែទាំសុខភាព ដែលមេធាវីការពារក្ដីទទួលបានទាក់ទិននឹងកូនក្ដីដែលមានវ័យចាស់ជរាទាំងនោះ និងពីបញ្ហាដែលមេធាវីការពារក្ដីមិនបានអនុញ្ញាតឲ្យជួបជាមួយនឹងកូនក្ដីរបស់ខ្លួន ខណៈពេលដែលកូនក្ដីទាំងនោះកំពុងទទួលការព្យាបាលនៅមន្ទីរពេទ្យ ។ បន្ថែមលើនេះ រ៉ូជី បានគូសបញ្ជាក់ថា ជនត្រូវចោទមានសិទ្ធិសម្រេចក្នុងការធ្វើឲ្យមានដំណើរការអង្គជំនុំជម្រះដែលលឿន និងមានសិទ្ធិសម្រេចចន្លោះពេលជាច្រើនខែរវាងអង្គសវនាការ និងសេចក្ដីសម្រេចទាក់ទិននឹងបញ្ហាណាមួយ ដែលមិនអាចទទួលយកបាន ។

## “ការលួចឯកសារ” ៖ គ្មានអំពើទុច្ចរិតក្លែងបន្លំទេ

ប៉ុន្មានសប្តាហ៍មុននេះ ការពិភាក្សាបានសម្រេចនូវកិច្ចព្រមព្រៀងគ្នាដ៏ល្អមួយទាក់ទិននឹងឯកសារសម្ងាត់របស់មេធាវីការពារក្តីសម្រាប់សំណុំរឿងលេខ០០២ ពីសំបុត្រមួយច្បាប់ទាក់ទិននឹង ហេឡែន ចារីស ប្រធានអង្គភាពជនរងគ្រោះរបស់ អ.វ.ត.ក ដែលទើបតែតែងតាំងនាពេលថ្មីៗនេះ ។ សំបុត្រមួយច្បាប់នេះត្រូវបានរកឃើញនៅបឹងមួយក្បែរ អ.វ.ត.ក ក្រោយមក សំបុត្រនេះបានចោទប្រកាន់ថាបានបោះចោលនៅក្នុងធុងមួយដើម្បីបំផ្លាញ ។ ខណៈពេលដែលការស៊ើបអង្កេតផ្ទៃក្នុងរបស់ អ.វ.ត.ក បានបញ្ចប់ទៅ ហើយរបាយការណ៍មួយកំពុងតែព្រៀងធ្វើឡើងដែលនឹងផ្តល់ព័ត៌មានលម្អិតទាក់ទិននឹងពាក្យដែលអ្នកកាសែតហៅថា “ការលួចឯកសារ” នោះអង្គភាពកិច្ចការសាធារណៈបានទទួចនិយាយថាគ្មានភស្តុតាងណាមួយបញ្ជាក់ពីការចោទប្រកាន់អំពើទុច្ចរិតក្លែងបន្លំ ឬចោរលួចឯកសារនោះទេ ។ នៅក្នុងរបាយការណ៍នោះ បុគ្គលិកសន្តិសុខរបស់ អ.វ.ត.ក នឹងត្រូវផ្តល់នូវអនុសាសន៍ថ្មី ដើម្បីពង្រឹងច្បាប់វិន័យក្នុងការបំផ្លាញឯកសារ ។

ទាក់ទិននឹងការបម្រុងចម្រាស់ប្រហាក់ប្រហែលគ្នានេះ អង្គភាពកិច្ចការសាធារណៈបានប្រកាសថា ណត រ៉ូសាញហូក (Knut Rosandhaug) អនុប្រធានផ្នែករដ្ឋបាល បានឆ្លើយតបនឹងសំបុត្រមួយច្បាប់របស់មេធាវី អៀង សារី ដែលសម្តែងនូវក្តីព្រួយបារម្ភពីការតែងតាំង ហេឡែន ចារីស ធ្វើជាប្រធានអង្គភាពជនរងគ្រោះដោយសារតែព័ត៌មាននេះមានជាប់ពាក់ព័ន្ធនឹងការចូលរួមរបស់ ហេឡែន ចារីស នៅក្នុងគណៈបក្សលេនីន ។ ជាក់ស្តែង សំបុត្រឆ្លើយតបរបស់ រ៉ូសាញហូក បានពន្យល់ថា បុគ្គលិករបស់ អ.វ.ត.ក ទាំងអស់មានសិទ្ធិទទួលបានសេរីភាពក្នុងការចូលរួម ហើយការចូលរួមពាក់ព័ន្ធផ្នែកនយោបាយរបស់ ហេឡែន ចារីស ក៏ត្រូវបានដឹងឮជាមុនរួចហើយដែរ ។ រ៉ូសាញហូក បាននិយាយថា លោកគាំទ្រយ៉ាងពេញទំហឹងលើការតែងតាំងរបស់ ហេឡែន ចារីស ។ អង្គភាពកិច្ចការសាធារណៈបាននិយាយថា នឹងគ្មានការបកស្រាយទាក់ទិននឹងបញ្ហានេះតទៅទៀតទេ ។